អក្សរឫទ្ធី
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ សេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្ស
## ថ្ងៃ១០ ធ្នូ ១៩៤៨ (ត) ។

www.hoksavann.org

ថ្ងៃទី២ មីនា ២០១២



មុននឹងចុះផ្សាយបន្តនូវមាត្រានៃធម្មនុញ្ញសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ យើងសូមធ្វើការសង្កេតនូវអត្ថន័យនៃមាត្រាទាំងនោះមានសេចក្តីមិនឲ្យមនុស្សបៀតបៀនគ្នារវាងមនុស្សក្នុងប្រទេសរបស់ខ្លួនក្តី រវាងជនជាតិដទៃក្តី ជាពិសេសរវាងប្រទេសនិងប្រទេសក្តី ។ បានសេចក្តីថា ច្បាប់បានបង្ហាញនូវសិទ្ធិនៃមនុស្សម្នាក់ៗ កុំឲ្យរដ្ឋាភិបាលនៃប្រទេសរបស់ខ្លួនរំលោភសិទ្ធិនេះ ផ្ទុយទៅវិញត្រូវការពារនូវសិទ្ធិទាំងនេះជូនប្រជាពលរដ្ឋ ។ បើប្រៀបធៀបខ្លឹមសារនៃពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធថា សេចក្តីសុខសន្តិភាពរបស់សង្គមមនុស្សកើតមកពីបុគ្គលម្នាក់ៗ ស្ងប់ផ្លូវចិត្តមិនធ្វើនូវអំពើបាបបៀតបៀនមនុស្សសត្វដទៃ ។ ពាក្យខ្លីប៉ុណ្ណេះ ហាក់ដូចជាក្រសោបអត្ថន័យនៃមាត្រាធម្មនុញ្ញនៃសិទ្ធិមនុស្សទាំងអស់តែម្តង ព្រោះពាក្យក្នុងមាត្រាទាំងនេះឲ្យគោរពសិទ្ធិ កុំឲ្យបៀតបៀនគ្នានេះឯង ។ សូមបន្តមាត្រានៃធម្មនុញ្ញនៃសិទ្ធិមនុស្សតទៅទៀត ។

★ មាត្រា២៣

១- បុគ្គលម្នាក់ៗមានសិទ្ធិធ្វើការ និងជ្រើសរើសមុខរបររបស់ខ្លួនដោយសេរី ក្នុងលក្ខណៈការងារត្រឹមត្រូវ ហើយមាន សិទ្ធិការពារទប់ទល់នឹងភាពអត់ការធ្វើ ។

២- មនុស្សគ្រប់រូបមានសិទ្ធិទទួលប្រាក់បៀវត្សរ៍ស្មើគ្នា ប្រសិនបើប្រកបការងារដូចគ្នា ដោយគ្មានការប្រកាន់បក្សពួកវណ្ណៈ ឬបុណ្យស័ក្តិឡើយ ។

៣- បុគ្គលដែលមានការងារធ្វើ មានសិទ្ធិទទួលបៀវត្សរ៍សមរម្យ អាចនឹងចិញ្ចឹមខ្លួននិងគ្រួសារបាន ដើម្បីឲ្យមានជីវភាពថ្លៃថ្នូរសមឋានៈជាមនុស្ស និងមានសិទ្ធិទទួលបន្ថែមលើបៀវត្សរ៍នេះ នូវមធ្យោបាយដទៃទៀតខាងផ្នែកសង្គមកិច្ច ប្រសិនបើមានការចាំបាច់ ។

៤- បុគ្គលម្នាក់ៗមានសិទ្ធិរួមគ្នាបង្កើតសហជីព ដើម្បីការពារផលប្រយោជន៍របស់ខ្លួន ។

★ មាត្រា២៤

បុគ្គលគ្រប់រូបមានសិទ្ធិឈប់សម្រាក និងលំហែកាយដោយរាប់ទាំងសិទ្ធិធ្វើការដែលមានកំណត់ពេលសមរម្យ និងឈប់សំរាកតាមកាលកំណត់ទៀងទាត់ ដោយមានប្រាក់បៀវត្សរ៍ផង ។

★ មាត្រា២៥

១- បុគ្គលម្នាក់ៗមានសិទ្ធិទទួលកម្រិតជីវភាពមួយល្មមគ្រប់គ្រាន់សំរាប់រក្សាសុខភាព សុខមាលភាពខ្លួន និងគ្រួសារខ្លួន រាប់ទាំងម្ហូបអាហារ សំលៀកបំពាក់ ផ្ទះសំបែង ការថែទាំជម្ងឺ និងជំនួយចាំបាច់ដទៃទៀតខាងផ្នែកសង្គមកិច្ច ។ បុគ្គលម្នាក់ៗមានសិទ្ធិទទួលការថែរក្សានៅពេលអត់ការធ្វើ ពេលមានជម្ងឺ ពេលធ្លាក់ខ្លួនពិការ មេម៉ាយ ពោះម៉ាយ ចាស់ជរា ឬក្នុងករណីឯទៀតដែលខ្លួនបាត់បង់នូវមធ្យោបាយចិញ្ចឹមជីវិត ដោយកាលៈទេសៈបង្ខិតបង្ខំ ។

២- មាតុភាព (ភាពជាម្តាយ) និងកុមារភាពមានសិទ្ធិទទួលការថែរក្សា និងទទួលនូវជំនួយសង្គ្រោះពិសេស ។ កុមារទាំងឡាយដែលកើតពីឪពុកម្តាយមានខាន់ស្លា ឬអត់ខាន់ស្លាក្តី ក៏ត្រូវបានការទទួលការការពារផ្នែកសង្គមកិច្ចដូចគ្នា ។

★ មាត្រា២៦

១- បុគ្គលម្នាក់ៗមានសិទ្ធិទទួលការអប់រំ ដោយហោចណាស់គឺការអប់រំជាមូលដ្ឋាននិងជាន់ដំបូង ដែលត្រូវធ្វើឡើងដោយឥតគិតថ្លៃ ។ ការអប់រំជាន់ដំបូងត្រូវតែឲ្យមានជាដាច់ខាត ។ ការអប់រំវិជ្ជាជីវៈបច្ចេកទេស ត្រូវបង្កើតឲ្យមានជាទូទៅ ។ ការបើកឲ្យចូលរៀនខាងផ្នែកឧត្តមសិក្សាត្រូវតែធ្វើឡើងដោយចំហឲ្យបានស្មើភាពគ្នា ដោយយកតែគុណសម្បត្តិរៀងៗខ្លួនជាមូលដ្ឋានប៉ុណ្ណោះ ។

២- ការអប់រំត្រូវមានគោលដៅទៅរកការរីកចំរើនពេញបរិបូណ៌នៃចរិតមនុស្ស និងទៅពង្រឹងការគោរពសិទ្ធិមនុស្ស និងសេរីភាពសំខាន់ៗទាំងឡាយ ។ ការអប់រំត្រូវផ្តល់ឲ្យមានការយោគយល់អត់ឱននិងមិត្តភាពរវាងប្រជាជាតិនានា រវាងពូជសាសន៍ និងក្រុមសាសនានានា និងជួយឲ្យមានការរីកចំរើនសកម្មភាពរបស់សហប្រជាជាតិក្នុងការទ្រទ្រង់សន្តិភាព ។

៣- ឪពុកម្តាយមានសិទ្ធិមុនគេក្នុងការជ្រើសរើសប្រភេទនៃការអប់រំសំរាប់ផ្តល់ដល់បុត្រធីតារបស់ខ្លួន ។

សូមបញ្ចប់មាត្រា២៦នេះសិន ពេលក្រោយនឹងបន្តទៅទៀត ។ មាត្រាដែលបានថែងមកនេះ គឺពណ៌នាអំពីសិទ្ធិការងារដើម្បីចិញ្ចឹមជីវិត បើមិនអាចធ្វើការចិញ្ចឹមជីវិតបានទេ ដូចជាពិការ ចាស់ជរាជាដើម ផ្នែកសង្គមកិច្ចរបស់រដ្ឋត្រូវធានាការរស់នៅរបស់ប្រជាពលរដ្ឋទាំងនោះ ។ ត្រង់នេះព្រះពុទ្ធសាសនាបានពោលអំពីប្រយោជន៍បច្ចុប្បន្ន ត្រូវសិក្សារៀនសូត្រនិងប្រកបវិជ្ជាជីវៈដើម្បីចិញ្ចឹមជីវិត ចំពោះការងារដែលឥតទោស ជៀសវាងមុខរបរប្រាសចាកផ្លូវធម៌និងរដ្ឋបានហាម ។ ថែមពីលើនេះទៀត ព្រះពុទ្ធបានណែនាំឲ្យប្រជាពលរដ្ឋនិងស្ថាប័នរដ្ឋ ធ្វើសង្គហទាន គឺទានដោយសង្គ្រោះចំពោះអ្នកក្រីក្រលំបាក អ្នកជរាពិការ ដែលពុំមានលទ្ធភាពធ្វើការងារចិញ្ចឹមជីវិត ។៚